**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជា អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## សំរេច

មាត្រា១.-

ត្រូវបានតម្លើងនាយកដ្ឋានរដ្ឋបាល និង បណ្តុះបណ្តាល របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ទៅជា " **អគ្គនាយកដ្ឋានរដ្ឋបាល** " នៃ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដោយបំបែកនាយកដ្ឋានរដ្ឋបាល និង បណ្តុះបណ្តាល ជាពីរនាយកដ្ឋាន គឺនាយកដ្ឋានរដ្ឋបាល និង នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល ។

មាត្រា២. -

ដាក់បញ្ចូលនាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាល ។

មាត្រា៣. -

អគ្គនាយកដ្ឋានរដ្ឋបាល ទទួលបន្ទុកគ្រប់គ្រងការងាររដ្ឋបាល បូកសរុបរបាយការណ៍ ឯកសារបុគ្គលិក ការងារបណ្តុះបណ្តាលក្របខ័ណ្ឌរបស់ក្រសួង ការងារសិក្សាស្រាវជ្រាវ និង សុពលភាពការងារសំរបសំរួលរាល់សកម្មភាពរដ្ឋបាល នៅក្នុងក្រសួង ជាមួយបណ្តាអង្គភាពមូលដ្ឋានខេត្ត-ក្រុង និងជាមួយបណ្តាក្រសួងនានា និង ការងារផែនការហិរញ្ញវត្ថុ សម្ភារៈបរិក្ខា សារពើភ័ណ្ឌ ។

អគ្គនាយកដ្ឋានរដ្ឋបាល ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាល របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មាននាយកដ្ឋានចំណុះចំនួន ០៣ :

១-នាយកដ្ឋានរដ្ឋបាល

២-នាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាល

៣-នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ

មាត្រា៤. -

នាយកដ្ឋានរដ្ឋបាល មានភារៈកិច្ច :

-សំរបសំរួលកិច្ចការទូទៅរបស់ក្រសួង នៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយអង្គភាពមូលដ្ឋានក្រោមឱវាទ
-គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេង ៗ របស់ក្រសួង
-ធានាប្រសិទ្ធិភាព និង សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
-សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេង ៗ របស់ក្រសួង ។

នាយកដ្ឋានរដ្ឋបាល ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ ។

មាត្រា៥. -

នាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាល មានភារៈកិច្ច :

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-រៀបចំរាល់លិខិតរដ្ឋបាល សំរាប់គ្រប់គ្រងអាជីព
-ធ្វើកម្មវិធីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង
-វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក
-រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ
-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពត៌មានប្រតិបត្តិ
-គ្រប់គ្រងការងារសង្គមរបស់ក្រសួង
-ទទួលកិច្ចការលើកសរសើរ និងជូនរង្វាន់
-រៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈអ្នកបច្ចេកទេស ប្រៃសណីយ៍ និង ទូរគមនាគមន៍
-បណ្តុះបណ្តាលកម្មករអ្នកបច្ចេកទេស អ្នកនាំសារ លេខាធិការ អ្នកត្រួតពិនិត្យ និងរៀបចំបង្រៀនវិក្រឹត្យការដល់បុគ្គលិក ។

នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលដឹកនាំដោយប្រធាននាយកដ្ឋានមួយរូបនិងអមដោយអនុប្រធាននាយកដ្ឋានជាជំនួយការ តាមការចាំបាច់ ។

មាត្រា៦. -

នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ មានភារៈកិច្ច :

-សិក្សា និងកសាងគំរោងផែនការអភិវឌ្ឍន៍លើមុខជំនាញប្រៃសណីយ៍ និង ទូរគមនាគមន៍ រយៈពេលមធ្យម និងរយៈពេលវែង
-កសាងគំរោងផែនការចំណូល-ចំណាយហិរញ្ញវត្ថុ

-គ្រប់គ្រងការងារប្រមូលចំណូលអាជីវកម្ម-សេវាកម្មលើមុខជំនាញប្រៃសណីយ៍ និង ទូរគមនាគមន៍
-គ្រប់គ្រងបេឡាសាច់ប្រាក់ជារៀល និងរូបិយប័ណ្ណតាមច្បាប់ហិរញ្ញវត្ថុជាធរមាន
-គ្រប់គ្រងសំភារៈ និងបរិក្ខាររបស់ក្រសួង
-គ្រប់គ្រងការងារលទ្ធកម្មសាធារណៈ
-គ្រប់គ្រងការងារវិក័យប័ត្រ
-គ្រប់គ្រងការងារសំណង់ វិស្វកម្ម
-អនុវត្តន៍ភារៈកិច្ចផ្សេង ៗ ទៀតដែលក្រសួងប្រគល់អោយ ។

មាត្រា៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

មាត្រា៩.-

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រីសូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ស្វូរ ឃុន

<u>កន្លែងទទួល</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៨ " <u>ដើម្បីអនុវត្តន៍</u>"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ